ល្បឿន និង សំទុះ

លោក ហ៊ុន សែន កំពុងយល់ច្រឡំអំពី ល្បឿន និង សំទុះ ព្រោះអ្វីដែលគាត់ បានធ្វើមកដល់ពេលនេះ គឺជាទង្វើគ្មាន ដើម និង ចុង ពោលថា គ្មាន ការពិចារណា។ ហេតុនេះឯង បានជាទង្វើនោះ រាបង្ហាញ នូវក្រហែងគ្រប់រូបភាព : ច្បាប់, យុទ្ធសាស្ត្រ និង ផែនការកលល្បិច...។ល។ កលយុទ្ធ ទប់ស្កាត់ជាមុន មិនឲ្យ គណបក្សសង្គ្រោះជាតិ មានលទ្ធភាព នឹងដណ្តើមអំណាចបានតាមការបោះឆ្នោត រាមានរូបភាពជា អំពើប្លន់អំណាចសុទ្ធសាធ ដោយគ្មានការអៀនខ្មាស់។ ភ្ជួលេខ នៃលទ្ធផល នៃការបោះឆ្នោតក្លែងក្លាយ រាបង្ហាញបន្ថែមទៀត នូវសំទុះទៅរកភាពមហិមា នៃការមើលងាយ ពីសំណាក់មតិជាតិ និង អន្តរជាតិ។ ចំណង់ហួសហេតុ ចង់ដូរ នូវកាលបរិច្ឆេទ នៃបបនកម្ម នៃរដ្ឋសភា និង រដ្ឋាភិបាល នៃអាណត្តិទី៦ រាជាសំទុះបន្ថែមទៅរកការមាក់ងាយជាក់ស្តែង ដល់ស្ថាប័នរាជានិយម ដោយយកតួអង្គព្រះមហាក្សត្រ អោយជួយកែន្ទ្ធ នូវទង្វើលួចប្លន់អំណាចអោយទៅជាអំពើស្របច្បាប់។

ពិតណាស់ហើយថា លោក ហ៊ុន សែន គាត់អាចនឹង ចូលប្រជុំនៅទីក្រុងព្រុចសែល ក្នុងជំនួបរវាង សហភាពអឺរ៉ុប និង អាស៊ាន ហើយនិង មហាសន្និបាត នៃអង្គការសហប្រជាជាតិ នៅខែ

ល្បឿន និង សំទុះ

កញ្ញាខាងមុខនេះ ព្រោះស្រុកខ្មែរជាសមាជិក នៃអាស៊ាន និង អង្គការសហប្រជាជាតិ តែវត្តមានគាត់នៅទីនោះ វាគ្មានសម្ហានុរូបភាព ជាតំណាង នៃប្រជាពលរដ្ឋទាំងអស់នោះឡើយ ព្រោះ គាត់ ជានាយករដ្ឋមន្ត្រីលួចឆ្នោត ឬ អ្នកដណ្តើមអំណាច។ តែ វត្តមានគាត់នៅពេលនោះ គាត់នឹងទាញយក ជាប្រយោជន៍ ផ្ទាល់ខ្លួន សំរាប់បង្ហាញ ដល់ខ្មែរប្រឆាំងនឹងគាត់ពេញមួយ នការ ថាគាត់ ជាមនុស្សខ្លាំងដដែល ហើយ គ្រប់អង្គការអន្តរ ជាតិ ទទួលស្គាល់គាត់ ជានាយករដ្ឋមន្ត្រីខ្មែរស្របច្បាប់។ លោក ហ៊ុន សែន មានគំនិតបែបនេះ ព្រោះគាត់ ជា មនុស្សអអារ្ស: គ្មានលក្ខណៈភាពនៅក្នុងស្មារតី របស់គាត់បន្ទិចនោះឡើយ។

សំទុះ នៃនយោបាយបន្ទន់អំណាច របស់លោក ហ៊ុន សែន ក្នុង ពេលនេះ វាកំពុងនាំស្រុកខ្មែរ ទៅរកមហន្តរាយពិតប្រាកដ ព្រោះ ស្រុកខ្មែរនឹងទទួលបន្ត នូវទណ្ឌកម្មយ៉ាងតឹងរ៉ឹង ជាការ បាញ់ស្រុះគ្នា ពីសំណាក់ សហរដ្ឋអាមេរិក, សហភាពអឺរ៉ុប និង ប្រទេសប្រជាធិបតី។ ពិតណាស់ហើយថា លោក ហ៊ុន សែន គាត់ អាង មានចិននៅពីក្រោយគាត់ និង ប្រទេសអប្រជាធិបតី មួយចំនួនតូច ទទួលស្គាល់របបគាត់ តែជញ្ជីងសេដ្ឋកិច្ច វា ច្បាស់ជាអវិជ្ជមាន ជាការនាំអោយ ខូចប្រយោជន៍ជាតិ ហើយ ប៉ះពាល់ផ្ទាល់ ដល់ការរស់នៅ នៃកម្មករ និង កសិករខ្មែរ ដូច យ៉ាង ជាបញ្ហាចម : រោងចក្របិទទ្វារ និង ការបង្កើតផលគ្រប់ យ៉ាងគ្មានផ្សារទិញ។ លោក ហ៊ុន សែន អាចបន្តការខ្មែរ ដែល

ល្បឿន និង សំទុះ

គាត់កេណ្ឌ អោយមកអង្គុយស្តាប់គាត់និយាយ អំពី ស្នាដៃ នៃការការក្សាសន្តិភាព, អភិវឌ្ឍន៍ និង ជ័យជំនះភ្លូកទឹកភ្លូនដី របស់គាត់ តែគាត់មិនអាច កុហកខ្មែរមួយនគរ និង សហគមន៍អន្តរជាតិបាននោះទេ ព្រោះអំពើដែលគាត់បានធ្វើ វាជាទង្វើមានភាពធំសំបើម ប្រឆាំងនឹង លទ្ធិប្រជាធិបតេយ្យ, ប្រឆាំងនឹង សិទ្ធិមនុស្ស និង យកតួអង្គព្រះមហាក្សត្រ មកបន្ទោកដើម្បី អញ្ជ នឹងបានអង្គុយ លើកៅអីអំណាច អោយបានទំនាន់ចិត្ត។ បើលោក ហ៊ុន សែន ជា មនុស្សខ្លាំង មានប្រជាប្រិយភាពពិត ចុះហេតុអ្វី ក៏ជនលាក់ពុតនេះ ត្រូវការជំនួយពី ហ្លួងខ្មែរ ? ព្រោះថា សំទុះ នៃគ្រប់ទង្វើដ៏ចង្រៃ របស់លោក ហ៊ុន សែន គឺ ជា ចំនួនបូករួម នៃការកំសាកជាទីបំផុតរបស់គាត់។ ការកំសាកនេះឯង ដែលនាំអោយបនក្នុំពេញ ប្រព្រឹត្ត នូវអំពើយោយៅគ្រប់បែបយ៉ាង ដើម្បីរក្សា នូវអំណាចខ្លួន។ ដូច្នោះ រដ្ឋសភា និង រដ្ឋាភិបាល ដែលនឹងកើតឡើង វាជាបន របស់បងធំ និង បងតូច ជុំមហាឆ្នេះ ទាំងនៅក្នុងស្រុក និង នៅក្រៅស្រុក។ ពិតណាស់ហើយថា លោក ហ៊ុន សែន គាត់មានមូលហេតុត្រឹមត្រូវ សំរាប់គាត់ ប្រព្រឹត្ត នូវអំពើលួចប្លន់ ព្រោះគាត់ មានសេចក្ដីត្រូវការ, មានកបិចិត្ត ដូច្នេះ ត្រូវតែគាត់ ធ្វើអោយបានសម្រេចយ៉ាងរហ័សជាទីបំផុត ដែលគេហៅថា តម្រេក នៃជនផ្តាច់ការ។